**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣៤ សសរ**

# សេចក្តីសំរេច

## ស្តីពី

## ការកែសំរួលសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ៥៨ សសរ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ ប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៥៨ សសរ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលការធ្វើដំណើរ និងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១:** ត្រូវបាននិរាករណ៍សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៥៨ សសរ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរ នៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ។

**ប្រការ២:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីសំរួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-ឯកឧត្តម ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២-ឯកឧត្តមនាយឧត្តមសេនីយ៍ នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |

www.pheakdeylaw.com

៣- ឯកឧត្តម គោស៊ុំ សារឿត រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន

៤-ឯកឧត្តមឧត្តមសេនីយ៍ឯក សុខ ផល អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៥-អភិបាលខេត្តជាប់ព្រំដែនដែលមានច្រកទ្វារអន្តរជាតិ អនុប្រធាន

៦-ឯកឧត្តម ស៊ឹម ចណ្ណា រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៧-ឯកឧត្តម តួច ចាន់កុសល រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៨-ឯកឧត្តម ជុំ អៀត រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៩-ឯកឧត្តម ហោ សារុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក និងជាលេខាធិការ

១០-ឯកឧត្តម លេខ ឌី អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ សមាជិក

១១-លោកឧត្តមសេនីយ៍ទោ ខៀវ ឆេន អគ្គនាយករងនៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ សមាជិក

១២ លោក ហាឡូ ប៊ុណ្ណាត់ អគ្គនាយករងនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៣-លោក ឡាយ ឫទ្ធី អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

១៤-លោកឧត្តមសេនីយ៍ទោ ថោង លីម ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

១៥-លោកឧត្តមសេនីយ៍ត្រី ញាណ ទិព្វល ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃអគ្គ-ស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ៣:** គណៈកម្មការអន្តរក្រសួងនេះ មានមុខងារ និងភារកិច្ចដូចតទៅ:

- ជំរុញអនុវត្តសេចក្ដីជូនដំណឹងលេខ៤១៣ សជណ សរ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី អោយមានប្រសិទ្ធិភាព ដើម្បីរៀបចំរបៀបរៀបរយ សណ្ដាប់ធ្នាប់ និងសំរួលការដឹកជញ្ជូន និងការធ្វើដំណើររបស់ភ្ញៀវទេសចរ និងអ្នកដំណើរនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត អោយបានល្អប្រសើរ ។
- សិក្សារៀបចំតំបន់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត អោយមានហេដ្ឋា - រចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រាន់ ដើម្បីសំរួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ ។
- លុបបំបាត់ និងបោសសំអាតភាពអសកម្មទាំងឡាយ និងភាពអនាធិបតេយ្យគ្រប់បែបយ៉ាង ដែលនាំអោយប៉ះពាល់ និងរំខានដល់ការធ្វើដំណើរ និងការដឹកជញ្ជូនអ្នកដំណើរ និងភ្ញៀវទេសចរ ។
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍ ដោយលើកយោបល់ជាវិធានការដោះស្រាយជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ៤:** គណៈកម្មការអន្តរក្រសួងនេះមានលេខាធិការដ្ឋានមួយជាជំនួយការដែលមានទីតាំងនៅក្រសួងទេសចរណ៍ និងចំណាយថវិការបស់ក្រសួងទេសចរណ៍ ។

www.pheakdeylaw.com

ប្រការ៥: សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៅតាមសំណូមពរ និងទំហំការងារជាក់ស្តែង ។

ប្រការ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួង-សាធារណការ និងដឹកជញ្ជូន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សាលាខេត្ត និងមន្ទីរទេសចរណ៍ខេត្តជាប់ព្រំដែនដែលមានច្រកទ្វារអន្តរជាតិ ប្រធាន អនុប្រធាន និងសមាជិកដែលមានរាយនាមក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ដូចប្រការ ៦
- -ឯកសារ-កាលប្បវត្តិ